**សលាកប័ត្រព័ត៌មាន ៖ អ្នកការពារសិទ្ធិមនុស្សនៅកម្ពុជា**
**កាលប្បវត្តិ ៖ ឆ្នាំ២០១៦**
**រូបភាពរួម ៖** អ្នកការពារសិទ្ធិមនុស្សនៅកម្ពុជាប្រឈមនឹងការយាយីតាមផ្លូវតុលាការ ការចាប់ខ្លួនតាមអំពើចិត្ត និងអំពើហិង្សាកាន់តែច្រើន។ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ("ម.ស.ម.ក") សូមអំពាវនាវឱ្យបញ្ឈប់ការយាយីទាំងនេះ និងស្នើឱ្យរាជរដ្ឋាភិបាលកម្ពុជា ("រដ្ឋាភិបាល") គោរពជាបន្ទាន់តាមកាតព្វកិច្ចជាតិ និងអន្តរជាតិក្នុងការការពារ និងគោរពសិទ្ធិអ្នកការពារសិទ្ធិមនុស្ស។

## សេចក្តីផ្តើម

អ្នកការពារសិទ្ធិមនុស្សនៅកម្ពុជាបន្តប្រឈមនឹងការយាយី ការគំរាមកំហែង និងអំពើហិង្សានានា ដែលជាការរំលោភបំពានច្បាប់ជាតិ និងអន្តរជាតិ រួមទាំងលិខិតុបករណ៍មួយចំនួនដែលបញ្ជាក់យ៉ាងច្បាស់ពីសារៈសំខាន់នៃអ្នកការពារសិទ្ធិមនុស្ស និងការងាររបស់ពួកគេ ព្រមទាំងកិច្ចការពារដែលត្រូវផ្តល់ជូនពួកគេ។ ម.ស.ម.ក តាក់តែងសលាកប័ត្រព័ត៌មាននេះឡើង ដើម្បីប្រារព្ធទិវាអ្នកការពារសិទ្ធិមនុស្សអន្តរជាតិឆ្នាំ២០១៦។ ម.ស.ម.ក ជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ មិនចូលបក្សសម្ព័ន្ធ ("អង្គការ") ដែលធ្វើការដើម្បីលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស ជាពិសេស សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនៅទូទាំងព្រះរាជាណាចក្រកម្ពុជា ("កម្ពុជា")។

## ក្របខ័ណ្ឌច្បាប់

ទោះបីជាច្បាប់ជាតិពុំមានបទប្បញ្ញត្តិចែងជាក់លាក់ចំពោះអ្នកការពារសិទ្ធិមនុស្សក៏ដោយ ក៏អ្នកការពារសិទ្ធិមនុស្សទទួលបានអត្ថប្រយោជន៍ពីការការពារ និងការធានាសិទ្ធិដែលបុគ្គលគ្រប់រូបទទួលបានតាមច្បាប់សិទ្ធិមនុស្សអន្តរជាតិ។ សេរីភាពជាមូលដ្ឋានខាងការបញ្ចេញមតិ និងការប្រមូលផ្តុំត្រូវបានការពារក្រោមមាត្រា៤១ នៃរដ្ឋធម្មនុញ្ញកម្ពុជា ហើយសេរីភាពខាងសមាគមត្រូវបានធានាដោយមាត្រា៤២ រីឯមាត្រា៣១ ទទួលស្គាល់ពីការអនុវត្តកិច្ចការពារសិទ្ធិមនុស្សដែលមានចែងនៅក្នុងសន្ធិសញ្ញាអន្តរជាតិនានាដែលប្រទេសកម្ពុជាបានផ្តល់សច្ចាប័ន។ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ឆ្នាំ២០០៧ បញ្ជាក់ពីការអនុវត្តកាតព្វកិច្ចដោយផ្ទាល់របស់កម្ពុជាតាមសន្ធិសញ្ញាអន្តរជាតិ។[1]

យន្តការ និងលិខិតុបករណ៍អន្តរជាតិជាក់លាក់មួយចំនួនចែងពីកិច្ចការពារច្បាស់លាស់សម្រាប់អ្នកការពារសិទ្ធិមនុស្ស។ សេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិ («អ.ស.ប») ស្តីពីអ្នកការពារសិទ្ធិមនុស្ស («សេចក្តី

[1] ក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា សេចក្តីសម្រេច លេខ ០៩២/០០៣/២០០៧ (ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៧)

ប្រកាសអ្នកការពារសិទ្ធិមនុស្ស»)[2] ជាលិខិតុបករណ៍អន្តរជាតិដំបូងគេដែលមានគោលបំណងចម្បងក្នុងការការពារអ្នកការពារសិទ្ធិមនុស្ស។ បើទោះពុំមែនជាលិខិតុបករណ៍ដែលចងកាតព្វកិច្ចផ្លូវច្បាប់ក្តី តែការអនុម័តជាឯកច្ឆន្ទលើសេចក្តីប្រកាសដោយមហាសន្និបាតរបស់ អ.ស.ប នេះ បង្ហាញពីការបោះជំហានដ៏សំខាន់មួយឆ្ពោះទៅរកការទទួលស្គាល់ជាអន្តរជាតិចំពោះការងាររបស់អ្នកការពារសិទ្ធិមនុស្ស និងបានបង្ហាញពីការប្តេជ្ញាចិត្តផ្នែកនយោបាយយ៉ាងមុតមាំរបស់សហគមន៍អន្តរជាតិក្នុងការការពារអ្នកការពារសិទ្ធិមនុស្ស។ សេចក្តីប្រកាសអ្នកការពារសិទ្ធិមនុស្សមិនបានបង្កើតសិទ្ធិថ្មីនោះទេ ប៉ុន្តែបញ្ជាក់ជាថ្មីម្តងទៀតពីតួនាទីជាក់លាក់មួយចំនួនរបស់អ្នកការពារសិទ្ធិមនុស្ស និងរដ្ឋនានា ព្រមទាំងបញ្ជាក់នូវសិទ្ធិក្នុងការលើកកម្ពស់ និងទាមទារឱ្យមានកិច្ចការពារ និងការទទួលស្គាល់សិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋាន សិទ្ធិសេរីភាពខាងការបញ្ចេញមតិនិងការប្រមូលផ្តុំដោយសន្តិវិធី ហើយនិងសិទ្ធិបង្កើត ចូលរួម និងចូលជាសមាជិកនៃអង្គការមិនមែនរដ្ឋាភិបាល សមាគម ឬក្រុមណាមួយ។ សេចក្តីប្រកាសអ្នកការពារសិទ្ធិមនុស្សនេះក៏គូសបញ្ជាក់ផងដែរពីតួនាទីរបស់រដ្ឋាភិបាលក្នុងការធានានូវកិច្ចការពារដល់ពួកគេ។ យោងតាមមាត្រា ១២ (២) អាជ្ញាធរពាក់ព័ន្ធត្រូវការពារអ្នកការពារសិទ្ធិមនុស្សមិនឱ្យមានការចាប់ខ្លួន អំពើហិង្សា ការគំរាមកំហែង ការសងសឹក និងការរើសអើងណាមួយដែលអាចកើតឡើងដោយសារសកម្មភាពជាអ្នកការពារសិទ្ធិមនុស្ស និងបញ្ជាក់យ៉ាងច្បាស់ថា អ្នកការពារសិទ្ធិមនុស្សត្រូវទទួលបានការការពារក្រោមច្បាប់ជាតិ។[3] នៅក្នុងខែវិច្ឆិកា ឆ្នាំ ២០១៣ គណៈកម្មាធិការទីបីនៃមហាសន្និបាត អ.ស.ប អនុម័តសេចក្តីសម្រេចលើកដំបូងដែលពុំធ្លាប់មានអំពីអ្នកការពារសិទ្ធិមនុស្សជាស្ត្រី ដែលដោះស្រាយហានិភ័យ ការរើសអើង និងអំពើហិង្សាជាក់លាក់មួយចំនួនដែលអ្នកការពារសិទ្ធិមនុស្សជាស្ត្រីបានប្រឈម។[4]

ក្នុងឆ្នាំ២០០០ គណៈកម្មការសិទ្ធិមនុស្សរបស់ អ.ស.ប[5] បានបង្កើតឱ្យមានអ្នករាយការណ៍ពិសេសស្តីពីស្ថានភាពរបស់អ្នកការពារសិទ្ធិមនុស្ស ("អ្នករាយការណ៍ពិសេស") ដែលជាផ្នែកមួយនៃអាណត្តិការងាររបស់ខ្លួន

---

[2] ដំណោះស្រាយនៃមហាសន្និបាតអង្គការសហប្រជាជាតិ «សេចក្តីប្រកាសស្តីពីសិទ្ធិ និងការទទួលខុសត្រូវរបស់បុគ្គល ក្រុម និងអង្គការសង្គមក្នុងការលើកកម្ពស់ និងការពារសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋានដែលទទួលស្គាល់ជាសកល» (ថ្ងៃទី០៨ ខែមីនា ឆ្នាំ១៩៩៩) ឯកសារ អ.ស.ប ក/ដំណោះស្រាយ/៥៣/១៤៤ http://bit.ly/19w8LEm

[3] ដូចលេខយោងខាងលើ មាត្រា ១២ (៣)

[4] មហាសន្និបាតអង្គការសហប្រជាជាតិ «ការផ្សព្វផ្សាយសេចក្តីប្រកាសស្តីពីសិទ្ធិមនុស្ស និងការទទួលខុសត្រូវរបស់បុគ្គល ក្រុម និងអង្គការសង្គមក្នុងការលើកកម្ពស់ និងការពារសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋានដែលទទួលស្គាល់ជាសកល នោះគឺ ការកាពារអ្នកការពារសិទ្ធិមនុស្សជាស្ត្រី» (ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៣) ឯកសារ អ.ស.ប ក/ដំណោះស្រាយ/៦៨/១៨១ http://goo.gl/yz4xwt

[5] គណៈកម្មការសិទ្ធិមនុស្ស អ.ស.ប ត្រូវបានជំនួសដោយក្រុមប្រឹក្សាសិទ្ធិមនុស្ស អ.ស.ប នៅក្នុងឆ្នាំ២០០៦។ សូមមើលគេហទំព័រការិយាល័យនៃឧត្តមស្នងការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ «ក្រុមប្រឹក្សាសិទ្ធិមនុស្ស» http://goo.gl/dr0bl

ដើម្បីជួយដល់ការអនុវត្តសេចក្តីប្រកាសអ្នកការពារសិទ្ធិមនុស្ស។[6] ក្នុងចំណោមការងារទាំងឡាយ អ្នករាយការណ៍ពិសេសអាចទទួលព័ត៌មាន និងពាក្យបណ្តឹងជាលក្ខណៈបុគ្គល[7]អំពីការរំលោភសិទ្ធិរបស់អ្នកការពារសិទ្ធិមនុស្ស និងអាចទំនាក់ទំនងជាមួយសមាជិករដ្ឋដែលពាក់ព័ន្ធនឹងករណីទាំងនេះ។ អ្នករាយការណ៍ពិសេសក៏ត្រូវធ្វើទស្សនៈកិច្ចនៅតាមប្រទេសដើម្បីស៊ើបអង្កេតស្ថានភាពរបស់អ្នកការពារសិទ្ធិមនុស្សក្នុងប្រទេសណាមួយ និងធ្វើរបាយការណ៍ប្រចាំឆ្នាំដាក់ទៅក្រុមប្រឹក្សាសិទ្ធិមនុស្ស អ.ស.ប ផងដែរ។

## តើអ្នកការពារសិទ្ធិមនុស្សជានរណា?

សេចក្តីប្រកាសអ្នកការពារសិទ្ធិមនុស្សឱ្យនិយមន័យអ្នកការពារសិទ្ធិមនុស្សថាជាមនុស្សគ្រប់រូប ជាបុគ្គល ឬ ក្រុម និងសមាគម ដែលធ្វើសកម្មភាពដើម្បីលុបបំបាត់ការរំលោភសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋានរបស់មនុស្ស និងបុគ្គលនានា។[8] សិទ្ធិទាំងនេះអាចជាសិទ្ធិពលរដ្ឋ នយោបាយ សេដ្ឋកិច្ច សង្គម និង/ឬ វប្បធម៌ និងអាចគ្របដណ្តប់លើបញ្ហានានាចាប់ពីការប្រកាន់ពូជសាសន៍ រហូតដល់ការបណ្តេញចេញដោយបង្ខំ។ ជារឿយៗ អ្នកការពារសិទ្ធិមនុស្ស គឺជាអ្នកមានវិជ្ជាជីវៈខាងសិទ្ធិមនុស្ស អ្នកសារព័ត៌មាន មេធាវី ឬ តំណាងសហគមន៍ ប៉ុន្តែមានបុគ្គលមួយចំនួនទៀតក៏មានលក្ខណៈសម្បត្តិជាអ្នកការពារសិទ្ធិមនុស្សផងដែរ។[9] ដើម្បីចាត់ទុកអ្នកណាម្នាក់ថាជាអ្នកការពារសិទ្ធិមនុស្សទៅបាន បុគ្គលនោះត្រូវតែពុំប្រព្រឹត្តអំពើហិង្សា ហើយត្រូវទទួលស្គាល់ពីសិទ្ធិមនុស្សជាសកល។[10] អ្នកការពារសិទ្ធិមនុស្សអាចធ្វើសកម្មភាពផ្សេងៗមួយចំនួនដូចជា ការចងក្រងករណីរំលោភសិទ្ធិមនុស្ស ការផ្តល់ការអប់រំ ឬ ការបណ្តុះបណ្តាលអំពីសិទ្ធិមនុស្ស ការទាមទារឱ្យមានការគោរពផ្នែកបរិស្ថាន និងការលើកកម្ពស់ការយល់ដឹងផ្សេងៗជាដើម។ល។[11]

## ស្ថានភាពអ្នកការពារសិទ្ធិមនុស្សនៅកម្ពុជា

ក្នុងអំឡុងពេលនៃការត្រួតពិនិត្យជាសកលតាមពេលវេលាកំណត់លើកចុងក្រោយរបស់កម្ពុជា នៅថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៤ រដ្ឋចំនួន៩ បានផ្តល់អនុសាសន៍ថា រដ្ឋាភិបាលកម្ពុជាគួរពង្រឹងនូវកិច្ចការពារអ្នកការពារសិទ្ធិមនុស្សឱ្យកាន់តែប្រសើរឡើង ឧទាហរណ៍ តាមរយៈការចូលរួមក្នុងកិច្ចសន្ទនាថ្នាក់ជាតិប្រកបដោយអត្ថន័យជាមួយ

---

[6] អ្នកស្រី ម៉ាការ៉េត សេហ្កាយ៉ា ទទួលតំណែងនេះពីឆ្នាំ២០០៨ ដល់ឆ្នាំ២០១៤ និងត្រូវបានបន្តតំណែងដោយលោក ម៉ៃហ្គេល ហ្វស្ស ដែលត្រូវបានតែងតាំងក្នុងខែមិថុនា ឆ្នាំ២០១៤។ សូមមើលគេហទំព័រ ការិយាល័យនៃឧត្តមស្នងការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ «អ្នករាយការណ៍ពិសេសលើស្ថានភាពអ្នកការពារសិទ្ធិមនុស្ស» http://bit.ly/1q1Hfc6

[7] បណ្តឹងបុគ្គលអំពីការចោទប្រកាន់ទៅលើអ្នកការពារសិទ្ធិមនុស្សអាចដាក់ទៅកាន់អ្នករាយការណ៍ពិសេស។ សូមមើលការិយាល័យនៃឧត្តមស្នងការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ «ការដាក់ពាក្យបណ្តឹង» http://bit.ly/1C4DJEi

[8] ដំណោះស្រាយមហាសន្និបាត អ.ស.ប (ន១) កថាខ័ណ្ឌទីបួនខាងដើម។

[9] ការិយាល័យនៃឧត្តមស្នងការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ(OHCHR) «សលាកបត្រព័ត៌មាន លេខ ២៩ ៖ អ្នកការពារសិទ្ធិមនុស្ស៖ ការការពារដល់សិទ្ធិការពារសិទ្ធិមនុស្ស» (ខែមេសា ឆ្នាំ២០០០៤) http://goo.gl/EnVkvy

[10] ដូចលេខយោងខាងលើ

[11] ដូចលេខយោងខាងលើ

អ្នកការពារសិទ្ធិមនុស្ស ការគោរពតាមបទដ្ឋានសេរីភាពខាងការបញ្ចេញមតិអន្តរជាតិ និងការបញ្ឈប់សកម្មភាពបំភិតបំភ័យ ឬការយាយីណាមួយ។[12] រដ្ឋាភិបាលបានទទួលយកអនុសាសន៍ភាគច្រើន ក្នុងនោះរួមមាន អនុសាសន៍ប្រាំពីរពាក់ព័ន្ធផ្ទាល់ទៅនឹងអ្នកការពារសិទ្ធិមនុស្សដូចជា ការស្នើរបស់សាធារណៈរដ្ឋឆែកឱ្យធ្វើវិសោធនកម្មលើក្រមព្រហ្មទណ្ឌ ព្រមទាំងច្បាប់ផ្សេងៗមួយចំនួនទៀតដើម្បីឱ្យស្របទៅតាមបទដ្ឋានសេរីភាពខាងការបញ្ចេញមតិអន្តរជាតិ និងទប់ស្កាត់ការយាយីទៅលើអ្នកការពារសិទ្ធិមនុស្ស អ្នកសារព័ត៌មាន និងអង្គការ ហើយប្រទេសអូទ្រីសផ្ដល់អនុសាសន៍ឱ្យគោរព និងការពារសិទ្ធិរបស់អ្នកការពារសិទ្ធិមនុស្ស និងអ្នកសារព័ត៌មានដើម្បីឱ្យអ្នកទាំងនេះអាចអនុវត្តការងាររបស់ខ្លួនដោយពុំមានការជ្រៀតជ្រែក ការបំភិតបំភ័យ ឬការយាយី។ តែយ៉ាងណាក្ដី រដ្ឋាភិបាលមិនបានគាំទ្រលើសំណើរបស់ប្រទេសទុយនេស៊ី ដែលតម្រូវឱ្យរដ្ឋាភិបាលធានានូវបរិយាកាសអំណោយផលសម្រាប់សកម្មភាពនានារបស់អ្នកការពារសិទ្ធិមនុស្សឡើយ ហើយក៏ពុំបានទទួលយកអនុសាសន៍របស់ប្រទេសព័រទុយហ្គាល់ដែលស្នើឱ្យរដ្ឋាភិបាលត្រូវការពារដល់អ្នកការពារសិទ្ធិមនុស្សពីការយាយី និងការចាប់ខ្លួនតាមអំពើចិត្ត និងបញ្ឈប់នូវរាល់ការរឹតត្បិតទៅលើបាតុកម្មដោយសន្តិវិធីនានាផងដែរ។[13]

ជាការគួរឱ្យសោកស្ដាយ នៅប៉ុន្មានខែចុងក្រោយនេះ យើងឃើញមានការបង្ក្រាបកាន់តែខ្លាំងឡើងទៅលើសង្គមស៊ីវិលពីសំណាក់រដ្ឋាភិបាល ដោយបានយាយី ចាប់ខ្លួន និងវាយដំទៅលើអ្នកការពារសិទ្ធិមនុស្សលេចធ្លោមួយចំនួន។ ម.ស.ម.ក បានកត់ត្រាទុកនូវការចាប់ខ្លួនចំនួន ៥៨ ករណីទាក់ទងនឹងការអនុវត្តសេរីភាពមូលដ្ឋានចាប់តាំងពីខែកក្កដា ដល់ខែកញ្ញា ឆ្នាំ២០១៦ ដែលជាការកើនឡើងខ្ពស់គួរឱ្យកត់សម្គាល់ ពី ៣៧ ករណី ដែលរាយការណ៍ក្នុងចន្លោះពេលបីខែមុន។ មកទល់ពេលនេះ មានការចាប់ខ្លួនចំនួន ៣៣ លើក ក្នុងការតវ៉ានៅក្នុងយុទ្ធនាការ «ថ្ងៃច័ន្ទពណ៌ខ្មៅ» ដែលពាក់ព័ន្ធនឹងបុគ្គលផ្សេងគ្នាចំនួន ២១ នាក់ ដែលក្នុងចំណោមអ្នកទាំងនោះធ្លាប់ត្រូវបានចាប់ខ្លួនច្រើនដង។ ការយាយីតាមផ្លូវតុលាការទៅលើអ្នករិះគន់រដ្ឋាភិបាលមានការកើនឡើងស្របពេលដែលមានការបង្កើតច្បាប់មួយចំនួនដែលមានលក្ខណៈរឹតត្បិតដែលប៉ះពាល់ជាខ្លាំងដល់អ្នកការពារសិទ្ធិមនុស្ស ដូចជាច្បាប់ស្ដីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល និងច្បាប់ស្ដីពីសហជីព ដែលរងការរិះគន់ខ្លាំងជាដើម។ ម្យ៉ាងទៀត បទប្បញ្ញត្តិមួយចំនួននៃក្រមព្រហ្មទណ្ឌកម្ពុជាកំពុងត្រូវបានអនុវត្តក្នុងករណីខ្លះៗ ដែលការអនុវត្តនោះបានប៉ះពាល់ជាខ្លាំងដល់អ្នកការពារសិទ្ធិមនុស្សដូចជា បទបរិហារកេរ្តិ៍ (មាត្រា ៣០៥ )[14] និងបទញុះញង់ (មាត្រា

---

[12] អៀរឡង់ សាធារណរដ្ឋឆែក អូទ្រីស ឈីលី នូវែលហ្សេឡង់ ប៊ែលហ្សិក បារាំង អាល្លឺម៉ង់ ព័រទុយហ្គាល់ និងទុយនេស៊ី បានផ្ដល់អនុសាសន៍ទៅលើប្រធានបទនោះ។ សូមមើល របាយការណ៍ ក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ «របាយការណ៍នៃក្រុមការងារលើការត្រួតពិនិត្យតាមកាលកំណត់លើប្រទេសកម្ពុជា» (ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៤) ឯកសារ អ.ស.ប ក/ក.ប.ស/២៦/១៦http://goo.gl/XzZk9M ។

[13] ដូចលេខយោងខាងលើ

[14] សូមមើលឧទាហរណ៍ ៖ «នីតិវិធីផ្លូវច្បាប់ប្រឆាំងនឹងបុគ្គលិកអង្គការសមធម៌» (ថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៦) http://bit.ly/2g9Dxgb «ករណីបរិហារកេរ្តិ៍លើលោក នី ចរិយា» http://bit.ly/2g9f0wD « អ្នកនាំពាក្យគណបក្សប្រជាជនកម្ពុជាដាក់ពាក្យបណ្ដឹងប្ដឹងលោកអ៊ូ វីរៈ

៤៩៤)[15] បទហិង្សាដោយចេតនា (មាត្រា ២១៧)[16] និងបទប្រឆាំងនឹងអ្នករាជការសាធារណៈ (៥០៣)[17] ព្រមទាំងការប្រើប្រាស់មធ្យោបាយណាមួយជាឧបសគ្គដល់ចរាចរណ៍សាធារណៈ ដែលជាបទចោទតាមមាត្រា ៧៨ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក។ល។[18]

អ្នកការពារសិទ្ធិមនុស្សក៏ប្រឈមនឹងការយាយីពីសំណាក់នគរបាលកាន់តែខ្លាំងដែរ។ ឧទាហរណ៍នៃការយាយីនេះមានដូចជា ការគំរាមចាប់ខ្លួន [19] ព្រមទាំងការចាប់ខ្លួនសកម្មជនដោយមិនត្រឹមត្រូវដែលក្រោយមកត្រូវបានដោះលែងវិញដោយពុំមានការចោទប្រកាន់។[20] នគរបាលក៏ជាប់ពាក់ព័ន្ធក្នុងការបំបែកការជួបជុំរបស់សកម្មជន និងអង្គការនៅមូលដ្ឋានតាមបណ្តាខេត្តមួយចំនួនផងដែរ[21] ដោយ ម.ស.ម.ក បានកត់ត្រាទុកករណីដោយឡែកពីគ្នាចំនួនបួនក្នុងខេត្តព្រះវិហារក្នុងចន្លោះពីខែមេសា ដល់ខែមិថុនា ឆ្នាំ២០១៦។ ជារឿយៗ ឧប្បត្តិហេតុនៃការយាយីទាំងនេះប្រព្រឹត្តឡើងដោយមានហិង្សាពីសំណាក់នគរបាល។ នាពេលថ្មីៗនេះ អ្នកឃ្លាំមើលសិទ្ធិមនុស្សម្នាក់បានរងអំពើហិង្សាពីសំណាក់នគរបាលក្នុងអំឡុងពេលហែក្បួនដោយសន្តិវិធី ដើម្បីប្រារព្ធទិវាសិទ្ធិលំនៅដ្ឋានពិភពលោក នៅថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៦ ក្នុងរាជធានីភ្នំពេញ។[22] ការគាបសង្កត់ និងការបំភិតបំភ័យជាបន្តបន្ទាប់របស់រដ្ឋាភិបាលមកលើអ្នកការពារសិទ្ធិមនុស្សនៅពេលបំពេញការងាររបស់ខ្លួនជាការចង្អុលបង្ហាញពីការរួមតូចនៃលំហលទ្ធិ

---

អ្នកវិភាគឯករាជ្យ ស្របពេលដែលអង្គភាពប្រឆាំងអំពើពុករលួយ កោះហៅបុគ្គលិកសង្គមស៊ីវិល» (ថ្ងៃទី២៦ មេសា ២០១៦) http://bit.ly/1pl1Kyt

[15] សូមមើលឧទាហរណ៍៖ «ការចោទប្រកាន់លើអ្នកស្រី ទេព វន្នី និងអ្នកស្រី បូវ សោភា» (ថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៦) http://bit.ly/2hhcEaY «និស្សិតកម្ពុជាម្នាក់ត្រូវបានកាត់ទោសរយៈពេល១៨ខែចំពោះការបង្ហោះសារនៅលើបណ្តាញហ្វេសប៊ុក» លីកាដូ (ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៦) http://bit.ly/2h5dSHp

[16] សូមមើលឧទាហរណ៍៖ «ថ្នាក់ដឹកនាំសហជីពចំនួនបួននាក់ និងបាតុករពីរនាក់រងរបួសក្នុងពេលការវាយតប់គ្នានៅពេលការតវ៉ានឹងក្រុមហ៊ុនកាពីតូលត្រូវបានចោទប្រកាន់» អង្គការលីកាដូ (ថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១៦) http://bit.ly/2h5uuRL «ការកាត់ទោសនិងការចោទប្រកាន់បន្ថែមទៅលើអ្នកការពារសិទ្ធិមនុស្សគឺអ្នកស្រី ទេព វន្នី » (ថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៦) អង្គការអ្នកការពារឈានមុខ(Front Line Defenders) http://bit.ly/2h1U1s9

[17] សូមមើលឧទាហរណ៍ «កម្ពុជា ៖ សកម្មជនដីធ្លីចំនួនបួននាក់ត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគាររយៈពេល ៦ ខែដោយសារ «ប្រមាថ និងរារាំងអ្នករាជការសាធារណៈ»(**AHRD**) (ថ្ងៃទី១៩ ខែកញ្ញា ២០១៦) http://bit.ly/2h23dN7

[18] សូមមើលឧទាហរណ៍៖ ម៉ិច ដារ៉ា « តុលាការកាត់ទោសសកម្មជនប្រាំពីរនាក់ដាក់ពន្ធនាគាររយៈពេល១ឆ្នាំ» សារព័ត៌មាន ខេមបូឌា ដេលី (ថ្ងៃទី១១ វិច្ឆិកា ២០១៤) http://bit.ly/2hrrsUC

[19] សូមមើលករណីឧទាហរណ៍ «កម្ពុជា៖ អាជ្ញាធរមូល ដ្ឋានបានគំរាមចាប់ខ្លួនសកម្មជនទាក់ទិននឹងការរៀបចំសិក្ខាសាលាស្តីពីសិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យ» (**AHRD**) (ថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០១៥) http://bit.ly/2gjiGdx

[20] សូមមើលករណីឧទាហរណ៍ «កម្ពុជា៖ រលកថ្មីនៃកំណត់មុខសញ្ញាចាប់ខ្លួនអ្នកការពារសិទ្ធិមនុស្សដើម្បីគំរាមកម្ទេចចោលសហគមន៍សិទ្ធិមនុស្សដែលសកម្ម» អង្គការ **FIDH** (ថ្ងៃទី០៩ ឧសភា ២០១៦) http://bit.ly/1UMZUcx

[21] ប៊ុត គីមសាយ «នគរបាលរារាំងការជួបប្រជុំរវាងអ្នករាយការណ៍ពិសេស និងអ្នកភូមិគួយ» សារព័ត៌មាន ដឹ ខេមបូឌា ដេលី (ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៦) http://bit.ly/1qgtrPW

[22] ប៊ិន សុខាន់ និងម៉ាហ្គេល ឌីកស៊ុន «កងការពារវាយដំមន្ត្រីអង្គការក្នុងអំឡុងការតវ៉ាក្នុងករណីដីធ្លី» សារព័ត៌មាន ដឹ ខេមបូឌា ដេលី (ថ្ងៃទី ១១ ខែតុលា ឆ្នាំ២០១៦) http://bit.ly/2dHh8rN

ប្រជាធិបតេយ្យយ៉ាងឆាប់រហ័សនៅកម្ពុជា ហើយបង្ហាញពីវិសាលភាពដែលរដ្ឋាភិបាលអាចបន្តធ្វើទៅទៀត ដើម្បីដាក់គំនាបលើអ្នកដែលហ៊ានរិះគន់នៅក្នុងដំណើរការឆ្ពោះទៅការបោះឆ្នោតនាពេលខាងមុខ។

**ករណីសិក្សា ៖ ការឃុំខ្លួនបណ្ដោះអាសន្នលើអ្នកការពារសិទ្ធិមនុស្សទាំង៥**

ចាប់តាំងពីខែមេសា ឆ្នាំ២០១៦ មក បុគ្គលិកនៃសមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា («សមាគមអាដហុក») ចំនួនបួនរូបរួមមាន លោក នី សុខា លោក យី សុខសាន្ត លោក ណៃ វ៉ង់ដា និងអ្នកស្រី លឹម មុនី និងលោក នី ចរិយា អតីតបុគ្គលិកសមាគមអាដហុក និងបច្ចុប្បន្នជាអគ្គលេខាធិការរងនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវបានឃុំខ្លួនលើបទចោទទាក់ទងនឹងការផ្ដល់ការប្រឹក្សាយោបល់តាមផ្លូវច្បាប់ទៅដល់កញ្ញា ខុម ចាន់តារ៉ាទី ដែលត្រូវបានស៊ើបអង្កេតបន្ទាប់ពីមានការចោទប្រកាន់ថា នាងមានទំនាក់ទំនងស្នេហាជាមួយលោក កឹម សុខា អនុប្រធានគណបក្សសង្គ្រោះជាតិ។ ក្រោយមក កញ្ញា ខុម ចាន់តារ៉ាទី បានចោទប្រកាន់អ្នកទាំងប្រាំនោះថា បានបញ្ចុះបញ្ចូលនាងឱ្យនិយាយកុហកក្នុងពេលសាកសួរ។ អ្នកទាំងប្រាំបានប្ដឹងជំទាស់នឹងសេចក្ដីសម្រេចបដិសេធលើសំណើសុំនៅក្រៅឃុំរបស់ពួកគាត់រហូតទៅដល់តុលាការកំពូល តែមិនបានជោគជ័យឡើយ បើទោះជាពុំមានសម្អាងហេតុណាមួយក្នុងចំណោមសម្អាងហេតុទាំងប្រាំមួយចំណុច សម្រាប់អនុវត្តការឃុំខ្លួនបណ្ដោះអាសន្នដែលមានចែងក្នុងមាត្រា ២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌត្រូវបានតុលាការផ្ដល់សម្អាងហេតុឱ្យបានច្បាស់លាស់ក្នុងករណីនេះយ៉ាងណាក្ដី។ អ្នកទាំងប្រាំមានគម្រោងប្ដឹងទៅតុលាការកំពូលម្ដងទៀតជំទាស់នឹងសេចក្ដីសម្រេចក្នុងការពន្យារការឃុំខ្លួនពួកគាត់រយៈពេលប្រាំមួយខែបន្ថែមទៀត។ ករណីនេះបានរងការរិះគន់ជាខ្លាំង រួមទាំងការរិះគន់របស់តំណាងពិសេស អ.ស.ប ចំនួនបួនរូប ដែលបានកត់សម្គាល់ថា ជាតុផ្សំក្នុងករណីនេះ «*បង្ហាញថាសាច់រឿងទាំងស្រុងនៃករណីនេះគឺគ្មានអ្វីក្រៅតែពីការធ្វើទុក្ខបុកម្នេញ ដោយហេតុផលនយោបាយទៅលើសង្គមស៊ីវិលនោះទេ*»។[23]

**ករណីសិក្សា ៖ ឃាតកម្មលើលោកបណ្ឌិត កែម ឡី**

នៅថ្ងៃទី១០ ខែកក្កដា នៅមុនម៉ោង៩ព្រឹក លោកបណ្ឌិត កែម ឡី អ្នកវិភាគនយោបាយដ៏ល្បីល្បាញត្រូវបានខ្មាន់កាំភ្លើងបាញ់សម្លាប់ទាំងកណ្ដាលថ្ងៃនៅស្ថានីយប្រេងឥន្ធនៈមួយកណ្ដាលរាជធានីភ្នំពេញ។ ឃាតកម្មនេះនាំឱ្យមានមនុស្សជាច្រើនធ្វើការប្រមូលផ្ដុំគ្នាភ្លាមៗ និងទាមទាររកយុត្តិធម៌នៅកន្លែងកើតហេតុ។ នាយករដ្ឋមន្ត្រី និងគណបក្សកាន់អំណាចបានប្រកាសថ្កោលទោសជាសាធារណៈចំពោះឃាតកម្មនេះ ហើយជនសង្ស័យដ៏សំខាន់នៅតែអះអាងថា ករណីនេះបណ្ដាលមកពីការជំពាក់ប្រាក់ចំនួន ៣.០០០ ដុល្លារអាមេរិក។ ទោះជាយ៉ាងណាក្ដី អ្នកតាមដានជាច្រើនអះអាងថា ឃាតកម្មលើលោកបណ្ឌិត កែម ឡី កើតឡើងដោយសារហេតុផលនយោបាយ ដោយ

---

[23] «អ្នកជំនាញសិទ្ធិមនុស្ស អ.ស.ប ជំរុញឱ្យកម្ពុជាបញ្ឈប់ការវាយប្រហារទៅលើសង្គមស៊ីវិល និងអ្នកការពារសិទ្ធិមនុស្ស» (ថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១៦) http://bit.ly/1XmYpmj

សារការរិះគន់មិនសំចៃមាត់របស់លោកទៅលើរដ្ឋាភិបាល។[24] កាតព្វកិច្ចរបស់កម្ពុជាក្រោមច្បាប់សិទ្ធិមនុស្សអន្តរជាតិ តម្រូវឱ្យធ្វើការស៊ើបអង្កេតដោយឥតលម្អៀង និងឯករាជ្យចំពោះឃាតកម្មនេះ ប៉ុន្តែនៅខណៈដែលជនសង្ស័យម្នាក់ត្រូវបានចាប់ខ្លួនភ្លាមៗក្រោយអំពើឃាតកម្មចាប់ពីពេលនោះមក ហាក់ដូចជាមានការវិវឌ្ឍតិចតួច ឬស្ទើរតែគ្មានសោះក្នុងការស៊ើបអង្កេតក្នុងករណីនេះ។[25]

**ករណីសិក្សា៖ ការចាប់ និងឃុំខ្លួនអ្នកស្រី ទេព វន្នី**

អ្នកស្រី ទេព វន្នី ជាសកម្មជនសហគមន៍បឹងកក់ដ៏លេចធ្លោមួយរូបត្រូវបានចាប់ខ្លួននៅថ្ងៃទី១៦ ខែសីហា បន្ទាប់ពីចូលរួមដោយសន្តិវិធីក្នុងយុទ្ធនាការ «ថ្ងៃច័ន្ទពណ៌ខ្មៅ» លើកទី១៥។ អ្នកសង្កេតការណ៍ជាច្រើនបានលើកឡើងថា អ្នកស្រី វន្នី ជាមួយនឹងអ្នកស្រី បូវ សោភា ដែលជាសកម្មជនបឹងកក់ដូចគ្នានោះ គឺជាគោលដៅពិសេសរបស់នគរបាលជាយូរណាស់មកហើយ ដោយសារប្រវត្តិសកម្មរបស់អ្នកទាំងពីរ។ កម្មសិក្សាការីជនជាតិអេស្ប៉ាញដែលធ្វើការស្រាវជ្រាវក្នុងសហគមន៍បឹងកក់ឈ្មោះ ម៉ាហ្គា ប៊ូចូហ្សា សេហ្គាឌូត្រូវបានចាប់ខ្លួនជាមួយសកម្មជនទាំងពីរនេះ ហើយត្រូវបាននីរទេសខ្លួនចេញពីកម្ពុជានៅព្រឹកបន្ទាប់។ នៅថ្ងៃទី២២ ខែសីហា អ្នកស្រី ទេព វន្នី និងអ្នកស្រី បូវ សោភា ត្រូវបានតុលាការកាត់ទោសពីបទ «ប្រមាថអ្នករាជការសាធារណៈ» បន្ទាប់ពីចៅក្រមបានប្តូរបទចោទក្នុងអំឡុងពេលសវនាការ ហើយកាត់ទោសដាក់ពន្ធនាគាររយៈពេល ៦ ប្រាំមួយថ្ងៃ។[26] ប៉ុន្តែ អ្នកស្រី ទេព វន្នី ត្រូវតុលាការបន្តឃុំខ្លួនទាក់ទងនឹងបទចោទផ្សេងទៀតគឺ ការប្រមាថ និងរារាំងអ្នករាជការសាធារណៈទាក់ទងនឹងការតវ៉ាមួយក្នុងខែវិច្ឆិកា ឆ្នាំ២០១១។ អ្នកស្រីត្រូវបានផ្តន្ទាទោសនៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៦ និងកាត់ទោសដាក់ពន្ធនាគាររយៈពេលប្រាំមួយខែ។ អ្នកស្រី ទេព វន្នី ប្រឈមនឹងបទចោទបន្ថែមយ៉ាងហោចចំនួនពីរទៀតទាក់ទិននឹងហេតុការណ៍ផ្សេងៗគ្នា។ បទចោទមួយគឺ អំពើហិង្សាដោយចេតនាពាក់ព័ន្ធនឹងបាតុកម្មដែលអ្នកស្រីបានដឹកនាំនៅមុខគេហដ្ឋានរបស់លោកនាយករដ្ឋមន្ត្រីនៅក្នុងឆ្នាំ២០១៣[27] និងបទចោទមួយទៀតដែលកំពុងស៊ើបអង្កេតគឺទាក់ទិននឹងបណ្តឹងពីបទជេរប្រមាថ និងគំរាមសម្លាប់កាលពីឆ្នាំ២០១២ ថ្វីបើដើមបណ្តឹងដែលជាអ្នកត្រូវគេ

---

[24] វិទ្យុអាស៊ីសេរី « ឃាតកម្មលើលោក កែម ឡី ពញ្ញាក់អារម្មណ៍ឱ្យងាកមកគិតពីបញ្ហានយោបាយនៅកម្ពុជា» (ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៦) http://bit.ly/2ggji3L

[25] យួន ណារិម និង ហ្វូច វ៉ាយត៍ « ភាពអសកម្មកើតឡើងក្នុងការស៊ើបអង្កេតលើឃាតកម្មលោក កែម ឡី» សារព័ត៌មាន *ដឹ ខេមបូឌា ដេលី* (ថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៦) http://bit.ly/2hm3FW0

[26] ឡាយ សាមាន «ដោះលែងសកម្មជនម្នាក់ ខណៈម្នាក់ទៀតនៅជាប់បទចោទ» សារព័ត៌មាន ភ្នំពេញប៉ុស្តិ៍ (ថ្ងៃទី២៣ ខែសីហា ២០១៦) http://bit.ly/2bKU4FS

[27] សេក ឧត្តម « លោកស្រី ទេព វន្នី ត្រូវតុលាការសាកសួរទាក់ទិននឹងបទចោទប្រកាន់នៅឆ្នាំ២០១៣» សារព័ត៌មាន *ដឹ ខេមបូឌា ដេលី* (ថ្ងៃទី៤ ខែវិច្ឆិកា ២០១៦) http://bit.ly/2gr1L91

បណ្ដេញចេញពីតំបន់បឹងកក់ដូចគ្នាបានដកពាក្យបណ្ដឹងយ៉ាងណាក្ដី។[28] ការសើរើរឿងចាស់ៗមកវិញដើម្បីដាក់សម្ពាធលើអ្នកការពារសិទ្ធិមនុស្សគឺជាយុទ្ធសាស្ត្រមួយដ៏ពេញនិយមរបស់អាជ្ញាធរ ក្នុងការបង្ក្រាបលើភាពសកម្ម។

**សេចក្ដីសន្និដ្ឋាន និងអនុសាសន៍**

ការយាយីជាបន្តបន្ទាប់ទៅលើអ្នកការពារសិទ្ធិមនុស្សក្នុងការបំពេញការងាររបស់ពួកគេបានក្លាយជារឿងដែលមជ្ឈដ្ឋានទូទៅដឹងឮអស់ទៅហើយនៅកម្ពុជា។ ក្នុងបំណងដើម្បីធានាឱ្យមានការគោរពសិទ្ធិអ្នកការពារសិទ្ធិមនុស្សនៅក្នុងប្រទេសកម្ពុជា និងផ្ដល់ឱកាសឱ្យពួកគេបានបំពេញការងារសំខាន់ៗរបស់ខ្លួនដោយពុំមានការភ័យខ្លាចផងនោះ ម.ស.ម.ក សូមស្នើរដ្ឋាភិបាល ដូចតទៅ ៖

- គោរពឱ្យបានពេញលេញតាមកាតព្វកិច្ចរបស់រដ្ឋាភិបាលក្នុងការការពារ និងគោរពសិទ្ធិរបស់អ្នកការពារសិទ្ធិមនុស្សក្រោមច្បាប់ជាតិ និងអន្តរជាតិ រួមទាំងអនុសាសន៍ទាំងឡាយដែលរដ្ឋនានាបានផ្ដល់ជូនរដ្ឋាភិបាលនៅអំឡុងពេលនៃការត្រួតពិនិត្យជាសកលតាមពេលវេលាកំណត់កាលពីឆ្នាំ២០១៤ ដែលបានរៀបចំដោយគណៈកម្មការសិទ្ធិមនុស្សរបស់ អ.ស.ប ហើយដែលអនុសាសន៍ទាំងនោះនៅមិនទាន់បានអនុវត្តនៅឡើយ។[29]
- ធានាឱ្យមានការស៊ើបអង្កេតឯករាជ្យ បន្ទាន់ និងហ្មត់ចត់ចំពោះឃាតកម្មលើលោកបណ្ឌិត កែម ឡី ដូចដែលច្បាប់សិទ្ធិមនុស្សអន្តរជាតិតម្រូវឱ្យរដ្ឋាភិបាលត្រូវមានកាតព្វកិច្ចបំពេញ និងស្វែងរកជំនួយជាអន្តរជាតិចំពោះការស៊ើបអង្កេតនេះ
- បញ្ឈប់នូវរាល់ការយាយីផ្នែកតុលាការ និងការយាយីផ្សេងៗទៀតទៅលើអ្នកការពារសិទ្ធិមនុស្ស និងដោះលែងអ្នកការពារសិទ្ធិមនុស្សដែលកំពុងតែជាប់ឃុំទាំងអស់ជាបន្ទាន់ ក្នុងនោះរួមមានទាំងបុគ្គលិកសមាគមអាដហុកដែលកំពុងជាប់ពន្ធនាគារទាំងបួនរូប និងលោក នី ចរិយា ដែលតុលាការពុំបានផ្ដល់សម្អាងហេតុផ្លូវច្បាប់ច្បាស់លាស់ក្នុងការបន្តឃុំខ្លួនបណ្ដោះអាសន្នលើអ្នកទាំងនេះ និងជាការរំលោភទៅលើច្បាប់ជាតិ និងអន្តរជាតិ។
- ពិនិត្យឡើងវិញនូវច្បាប់ដែលបានអនុម័តហើយជាពិសេស ច្បាប់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល និងច្បាប់ស្ដីពីសហជីព ក៏ដូចជាច្បាប់ផ្សេងទៀត ដែលមានលក្ខណៈរឹតត្បិតលើសកម្មភាពរបស់អ្នកការពារសិទ្ធិមនុស្សដូចជា បទប្បញ្ញត្តិពាក់ព័ន្ធមួយចំនួននៃក្រមព្រហ្មទណ្ឌកម្ពុជា ដោយបញ្ចូលមតិយោបល់ដែលជាតុចូលសំខាន់ៗពីតួអង្គសង្គមស៊ីវិល និងធ្វើវិសោធនកម្មបទប្បញ្ញត្តិទាំងនោះដើម្បីឱ្យស្របទៅតាមរដ្ឋធម្មនុញ្ញ និងច្បាប់សិទ្ធិមនុស្សអន្តរជាតិ។

---

[28] សេក ឧត្តម « ស្ត្រីចំណាស់នៅបឹងកក់បដិសេធថាបានធ្វើការគំរាមកំហែង» សារព័ត៌មាន ដឹ ខេមបូឌា ដេលី (ថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០១៦) http://bit.ly/2hr6Knz

[29].សូមមើលលេខយោង១២

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទាក់អ្នកស្រី ឆាយ ឈុនលី អ្នកសម្របសម្រួលគម្រោងការពារសេរីភាពមូលដ្ឋាន របស់ ម.ស.ម.ក តាមរយៈទូរសព្ទ ៖ +៨៥៥ (0) ១៧ ៥២៨ 0២១ ឬអ៊ីម៉ែល chhunly.chhay@cchrcambodia.org ឬ លោក ផាត់ ដឺប្រ៊ូន ទីប្រឹក្សាច្បាប់ ម.ស.ម.ក តាមរយៈទូរសព្ទ៖ +៨៥៥ (0) ៨៩ ៥៣ ៦២ ១៥ ឬ អ៊ីម៉ែល ៖ pat.debrun@cchrcambodia.org ៕